ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១០៥៩ កសក

# លិខិតបញ្ជូន

គោរពជូន: -ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង

| ល.រ | កាលបរិច្ឆេទលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | -របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំឆ្នាំ២០១៨** និងទិសដៅអនុវត្តបន្ត.................................... | ០១ច្បាប់ | "ដើម្បីជូនជ្រាប" --------- |

ថ្ងៃ ៣ ១០ រោច ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៩

ត.ប រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គលេខាធិការ

ស្រី វុឌ្ឍី

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សកម្មភាពការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ២០១៨ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងឆ្នាំ២០១៨នេះ តាមការកត់សម្គាល់ឃើញថា ការងារបង្កបង្កើនផលស្រូវរដូវវស្សានៅទូទាំងប្រទេសបានបញ្ចប់ហើយដោយសម្រេចបានចំនួន ២ ៧៣៥ ៨៤០ហ.ត ស្មើនឹង១០៨,៨៣% នៃផែនការ ២ ៥១៣ ៨៩៥ហ.ត។ ការប្រើប្រាស់គ្រឿងយន្តសម្រាប់ការរៀបចំដីផលិតកម្មដំណាំស្រូវគឺស្មើនឹង៩៦,៤៣% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របីមាន ៣,៥៧% រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល ក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងឆ្នាំ២០១៨នេះគឺ ការរៀបចំវេទិកាកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការរៀបចំវេទិកាកសិករឆ្នើម ការរៀបចំពិធីសន្និបាតកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការរៀបចំកិច្ចប្រជុំសំខាន់ៗ ការទទួលជួបភ្ញៀវជាតិ-អន្តរជាតិ ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសជាច្រើន រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងឆ្នាំ២០១៨នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះរដូវវស្សាឆ្នាំ២០១៨

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៣ ០០៣ ២២៣ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១០៧ ១១៤ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ៨៩៦ ១០៩ហ.ត លើសឆ្នាំមុនចំនួន ៥៧ ៨៦២ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៣២ ៧៦៤ហ.ត តិចជាងឆ្នាំមុនចំនួន ៩ ១៦៩ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៧៣៥ ៨៤០ហ.ត ស្មើនឹង ១០៨,៨៣% នៃផែនការ ២ ៥១៣ ៨៩៥ហ.ត លើសឆ្នាំមុនចំនួន ៧៨ ០៧២ហ.ត។

#### ១.២ ការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៨

ការងារប្រមូលផលស្រូវរដូវវស្សាសម្រេចបានចំនួន ២ ៤២០ ៣៧៦ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៧ ៤៣៥ ២៤៦តោន លើសឆ្នាំមុនចំនួន ២៥០ ៣៤០តោន។ ទិន្នផលគិតជាមធ្យម ៣,០៧២តោន/ហ.ត លើសឆ្នាំមុនចំនួន ៥៧គ.ក្រ/ហ.ត។

#### ១.៣ ផលិតកម្មដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៨-២០១៩

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងគិតត្រឹមថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៤៩៣ ០៤០ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៦ ២០៤ហ.ត និងដោយគ្រឿងយន្តមានចំនួន ៤៨៦ ៨៣៦ហ.ត លើសឆ្នាំមុនចំនួន ១៤៤ ៦៩៨ហ.ត

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ ៖(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ ៖ (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- ផ្ទៃដីសាបសម្រេចបានចំនួន ១៦១ហ.ត លើសឆ្នាំមុនចំនួន ១១ហ.ត
- ផ្ទៃដីស្ពង និងព្រោះសម្រេចបានចំនួន ៤៧៣ ៧៤៥ហ.ត ស្មើនឹង ១០៥,៨៦% នៃផែនការ ៤៤៧ ៤០០ហ.ត លើសឆ្នាំមុនចំនួន ១៤១ ៨៨២ហ.ត។

### ១.៤ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៨-២០១៩

-ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ២០ ៣៦៨ហ.ត ស្មើនឹង៦៤,៤៩% នៃផែនការ ៣១ ៥៨៤ហ.ត លើសឆ្នាំមុនចំនួន ៨ ៦៣៦ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៥៦ ៦០៥ហ.ត ស្មើនឹង៥៣,០៤% នៃផែនការ ១០៦ ៧១៣ហ.ត លើសឆ្នាំមុនចំនួន ២៨ ៤៤២ហ.ត។

### ១.៥ ការនាំចេញអង្ករ

ក្នុងខែធ្នូ ឆ្នាំ២០១៨នេះ ការនាំអង្ករចេញតាមរយៈច្រកចេញ-ចូលតែមួយគឺមានបរិមាណសរុបចំនួន ១២៨ ៩៨៥តោន ដែលមានការកើនឡើងចំនួន ៥៥ ៥៤៣តោន (+៤៣%) ធៀបនឹងបរិមាណនាំចេញក្នុងខែធ្នូ ឆ្នាំ២០១៧។ សរុបរយៈពេល ១២ខែ ឆ្នាំ២០១៨ នាំចេញបានចំនួន ៦២៦ ២២៥តោន ការនាំចេញទៅកាន់ទិសដៅចំនួន ៦១ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ (១៧០ ១៥៤តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៨៦ ០៥០តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៣ (៤០ ៨៦១តោន) ប្រទេសហ្គាបុងឈរលំដាប់ទី៤ (៣៣ ០៦០តោន) ប្រទេសណេដឺឡែនឈរលំដាប់ទី៥ (២៦ ៧១៤តោន) ប្រទេសវៀតណាមឈរលំដាប់ទី៦ (២៦ ៧១២តោន) ប្រទេសថៃឈរលំដាប់ទី៧ (២៣ ៨០៦តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៨ (២៣ ១៤២តោន) ប្រទេសប៊ែលហ្ស៊ិកឈរលំដាប់ទី៩ (១៩ ១៧៧តោន) និងប្រទេសអង់គ្លេសឈរលំដាប់លេខទី១០ (១៨ ១៧៨តោន) ហើយបច្ចុប្បន្នការនាំចេញអង្ករមានចំនួន ៨៧ក្រុមហ៊ុន។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| លរ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហត) | ផលិតផលអនុវត្តបានប្រចាំឆ្នាំ (តោន) | បញ្ចាញលក់ប្រចាំឆ្នាំ (តោន) |
|---|---|---|---|---|---|
| I.ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៦៧០ | ៨០១ | ៥៣៨ | ៥៥០ |
| សរុប I | | ៦៧០ | ៨០១ | ៥៣៨ | ៥៥០ |
| II. ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុនសុភក្តិនិកា អ៊ីនវេសមេនគ្រុប | ១២ ៣១០ | ១៥ ១៨០ | ១៥ ៩១៧ | ១៦ ៩០៦ |
| ២ | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | ១ ១៩១ | ២ ១០៥ | ១ ៦១៦ | ១ ៥៧៥ |
| ៣ | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៥៦៣១ | ៨ ៤៤០ | ៤ ៤០៣ | ៤ ៦៥៦ |
| ៤ | ក្រុមហ៊ុន ស៊ីហ្វរ៉ាប់ប៊ើលីមីធីត (រតនគិរី) | ៧៩ | ២ ៦៦៦ | ១៣៦ | ៣៤៧ |
| ៥ | ក្រុមហ៊ុនស៊ីហ្វរីសសស៍(ស្នួល) | ៣ ៨៥៩ | ៤ ៤០៦ | ៤ ៦០៣ | ៤ ៩៦១ |
| ៦ | ក្រុមហ៊ុន ឡុង ស្រេង | ៣ ៣៤៣ | ៤ ១៨៧ | ៥ ២៥១ | ៤ ៧២៣ |
| ៧ | ក្រុមហ៊ុន អានម៉ារ៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៨៤៨ | ៥ ២៦៣ | ២ ៦៦៦ | ២ ៤៩៨ |
| ៨ | ក្រុមហ៊ុនអានម៉ារ៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ១ ៩០១ | ៣ ១៦៦ | ១ ៤៣០ | ១ ៣៥២ |
| ៩ | ក្រុមហ៊ុនក្រែក(ខេមបូឌា)ខូអិលធីឌី | ៤ ៣៥៩ | ៤ ៧៩៨ | ៥ ៨៣២ | ៥ ៣៦១ |
| សរុបII | | ៣៦ ៥២១ | ៥០ ២១១ | ៤១ ៨៥៤ | ៤២ ៣៧៩ |
| III. ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៤៤ ៩២២ | ២២៤ ៥៦៧ | ៤៨ ១៩៨ | ៤៦ ១០០ |
| ២ | ចម្ការកៅស៊ូគ្រួសារ | ១១៩ ៨៣៧ | ១៦១ ១០៣ | ១២៩ ៥១០ | ១២៨ ៤៧១ |
| សរុប III | | ១៦៤ ៧៥៨ | ៣៨៥ ៦៧០ | ១៧៧ ៧០៨ | ១៧៤ ៥៧១ |
| សរុប I + II + III | | ២០១ ៩៥០ | ៤៣៦ ៦៨២ | ២២០ ១០០ | ២១៧ ៥០០ |

គួរកត់សម្គាល់ថាជ័រកៅស៊ូក្នុងខែធ្នូ ឆ្នាំ២០១៨នេះមានតម្លៃជាមធ្យម ១ ២១៣ដុល្លារ/តោន។

## ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានចូលរួមសិក្ខាសាលាស្តីពីការអនុវត្តចំណូល ចំណាយថវិកា១០ខែ ឆ្នាំ២០១៨ និងបញ្ហាប្រឈម
- បានត្រួតពិនិត្យតាមដានការលាយថ្នាំរំញោច Ethephon គ្រប់ការពិសោធទាំងអស់
- បានចុះបញ្ជិកាពិសោធន៍យថាប្រភេទកៅស៊ូកម្ពុជាឱ្យក្រុមហ៊ុនសុភក្តិនិកា អ៊ិនវេសមេនគ្រុប ខូ., អិលធីឌី
- បានចុះបញ្ជិកាពេងចក្រកែច្នៃយថាប្រភេទកៅស៊ូ និងមន្ទីរពិសោធន៍យថាប្រភេទកៅស៊ូកម្ពុជាឱ្យក្រុមហ៊ុនស៊ីហ្វ-វីសសស៍ លីមីធិត
- វិភាគបរិមាណជ័រស្ងួត DRC លើចម្ការពិសោធន៍នីមួយៗតាមវិធីសាស្ត្រដុត និងតាមមន្ទីរពិសោធន៍
- បានវិភាគសរីសាស្ត្រទឹកជ័រ LD ចំនួន ៩ចម្ការពិសោធន៍គឺ AA01 AA02 AA07 AA09 SSCT01 IRAE03 IRAE06 IRAE08 IRAE09
- ថែទាំកូនកៅស៊ូស៊ីដលីង ច្បារបង្កាត់ពូជ SET02 និង SSCT02
- បានចូលរួមសន្និសីទកៅស៊ូអន្តរជាតិនិងកិច្ចប្រជុំប្រចាំឆ្នាំរបស់ IRRDB នៅប្រទេសកូតឌីវ័រ
- ថែទាំដំណាំចន្លោះរងកៅស៊ូចំនួន ៥ប្រភេទគឺ ចេក ខ្នុរ ស្វាយ ម្នាស់ និងស្វាយចន្ទី។

## ៣ ផ្នែកកសិ-ឧស្សាហកម្ម

- បានរៀបចំសិក្ខាសាលាស្តីពីការផ្សព្វផ្សាយគុណភាពសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម
- បានចុះបណ្តុះបណ្តាលកសិករអំពីបច្ចេកទេសកែច្នៃ បន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិ
- បានចុះបើកវេទិកាផ្សព្វផ្សាយស្តីពីការជំរុញការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាក្រោមលក្ខខណ្ឌវិនិយោគ
- បានពិនិត្យសំណាកចំនួន ៨៥មុខ មានបន្លែ ផ្លែឈើ អាហារកែច្នៃ សាច់ និងស៊ុតដែលចុះជ្រើសរើសពីផ្សារសំខាន់ៗចំនួន៣
- បានពិនិត្យសំណាកអង្ករចំនួន ១១ប្រភេទ និងបន្លែ ៥ប្រភេទ ដោយបានរកឃើញកាកសំណល់គីមី និងថ្នាំពុលកសិកម្ម
- បានអនុវត្តសកម្មភាពលើការវិភាគបឋមសំណាកចំនួន ១៨មុខ ដែលជាអាហារកែច្នៃបានប្រមូលពីផ្សារ ដើម្បីរកវត្តមានបូរ៉ាក់ដែលជាសមាសធាតុគីមីសម្រាប់លាយផ្សំជាមួយវត្ថុធាតុដើមធ្វើឱ្យមានភាពស្វិត និងរក្សាទុកបានយូរ
- បានធ្វើការវិភាគរកបរិមាណប្រូតេអ៊ីននៅក្នុងអង្ករ អាហារកែច្នៃ និងអាហារផ្គាប់លើសំណាកចំនួន ៣៧មុខ
- បានចុះពង្រឹងមន្ត្រីការិយាល័យកសិ-ឧស្សាហកម្មរាជធានី-ខេត្ត២៥ លើការងារអនុវត្តយន្តការកិច្ចសន្យា ស្ថិតិនៃការកែច្នៃសុវត្ថិភាពចំណីអាហារ។

## ៤ ផ្នែករុក្ខាព្រៃឈើ

### ៤.១ ការងារព្រៃឈើ

- បណ្តុះបណ្តាលសមត្ថភាពបច្ចេកទេសប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) និងប្រព័ន្ធកំណត់ទីតាំងលើផែនដី (GPS) ជូនមន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើព្រៃវែង កំពត កំពង់ឆ្នាំង សៀមរាប ឧត្តរមានជ័យ និងខេត្តស្វាយរៀងដែលមានមន្ត្រីចូលរួមសរុបចំនួន ៨៤ រូប
- បានចេញប្រកាសស្តីពីការបង្កើត និងគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ៣១កន្លែង មានផ្ទៃដីព្រៃទំហំ ៣៥ ៨៩៦,៦៦ហ.ត ក្នុងនោះខេត្តព្រះវិហារចំនួន ០៩កន្លែង មានផ្ទៃដីទំហំ ១៨ ៧២១ហ.ត
- បានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ជាមួយខណ្ឌរដ្ឋបាលព្រៃឈើចំនួន ០៤លើក ដែលមានផ្ទៃដីសរុបទំហំ ២៧ ៨៩១ហ.ត
- ចុះបើកវគ្គផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ការគ្រប់គ្រង និងការអនុវត្តលិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងសហគមន៍ព្រៃឈើ ផលប្រយោជន៍ព្រៃសហគមន៍ និងនីតិវិធីទប់ស្កាត់បទល្មើសព្រៃសហគមន៍ចំនួន ២៨វគ្គ
- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តសរុបចំនួន ៧៧គ្រឿង និងយានយន្តចំនួន ៨៥គ្រឿង ជូនក្រុមហ៊ុន និងអតិថិជនចំនួន ១២។

### ៤.២ ការងារអភិរក្សសត្វព្រៃ

- សហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋានចុះអន្តរាគមន៍ទប់ស្កាត់ និងបង្ក្រាបការជួញដូរសត្វព្រៃចំនួន ១០លើក នៅខេត្តកំពង់ស្ពឺ ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី ព្រះសីហនុ ពោធិ៍សាត់ និងខេត្តព្រះវិហារ

- បានចុះសិក្សាស្រាវជ្រាវ និងធ្វើការតាមដានវត្តមានសត្វព្រៃចំនួន ០៨លើក នៅខេត្តស្ទឹងត្រែង បាត់ដំបង ព្រះវិហារ សៀមរាប ពោធិ៍សាត់ និងខេត្តកោះកុង ដោយកត់ត្រាសត្វព្រៃសំខាន់ៗចំនួន ២៣៦ប្រភេទ ក្នុងនោះមានថនិកសត្វចំនួន ៦១ប្រភេទ សត្វស្លាបចំនួន ១៤៧ប្រភេទ និងឧរង្គសត្វចំនួន ២៨ប្រភេទ

- ចុះធ្វើជំរឿនសត្វស្វានៅតាមទីសាធារណៈ និងតំបន់សួនសត្វនៅរាជធានីភ្នំពេញ កណ្តាល តាកែវ កំពង់ស្ពឺ កំពង់ចាម ក្រចេះ កំពង់ធំ បាត់ដំបង និងខេត្តព្រះសីហនុ ដោយរាប់ឃើញសត្វស្វាចំនួន ២ ៩៧០ក្បាល

- សហការជាមួយអង្គការ FFI ចុះដាក់ម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ៣២គ្រឿង សម្រាប់តាមដានវត្តមាន សត្វដំរី និងប្រភេទសត្វព្រៃផ្សេងៗទៀត នៅតំបន់ជួរភ្នំក្រវាញ ក្នុងភូមិសាស្ត្រវាលតាភូ ក្នុងឃុំអណ្តូងទឹក ស្រុកកោះកុង និងតំបន់ជីផាត (អូរកី) ក្នុងភូមិសាស្ត្រឃុំជីផាត តំបន់ថ្មបាំង ស្ថិតក្នុងឃុំឫស្សីជ្រុំ និងតំបន់ អារ៉ែង ឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង។

## ៤.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន ៦ ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៧ទីតាំង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង មានស្វាក្តាមសរុបចំនួន ៥៣ ៩២៤ក្បាល ក្នុងនោះកូនកើតក្នុងខេចំនួន ១១ ៨១៣ក្បាល ដឹកជញ្ជូនក្នុងស្រុកចំនួន ២ ១៣១ក្បាល និងនាំចេញទៅក្រៅប្រទេសចំនួន ១០ ៧៦២ក្បាល

- សម្រាប់ឆ្នាំ២០១៨ នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៦២៩ក្បាល (បក្សីចំនួន ៥៤ប្រភេទ ថនិកសត្វចំនួន ៤១ប្រភេទ និងល្មូនចំនួន ១២ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ១ ៧៦៩ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ២៤៤ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ១ ៣០៦ក្បាល។ ដោយឡែក គម្រោងអភិរក្សព្រៃកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិៈ ក្រុមល្បាតសហគមន៍ចំនួន ៣០នាក់ បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗ ចំនួន ៥រួមមាន នៅអារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- បានជួសជុលលុបផ្លូវសំបុកមាន់ក្រាលក្រួសក្រហមបានប្រវែង ១២ ៥៣៦ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃបានទំហំ ៥៨ហ.ត។

## ៤.៤ ការងារដាំដើមឈើ

- បានបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើត្រពាំងព្រះនៅលើដីសាធារណៈរបស់រដ្ឋ ដែលមានផ្ទៃដីសរុបទំហំ ៧ ២៤៣ ៦០៥$ម^២$ និងមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន ២០៣ប័ណ្ណ

- បានស្នើសុំចុះបញ្ជីដីរដ្ឋ និងរៀបចំឯកសារស្នើសុំបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ៣៨ទីតាំង មានផ្ទៃដីសរុបទំហំ ២១១ ៩២២,៣១ហ.ត

- អនុវត្តគម្រោងដាំឈើជាចម្ការថ្មីទំហំ ១៥២ហ.ត នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ២ទីតាំង គឺស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម និងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរថ្មខេត្តព្រះសីហនុ។

## ៤.៥ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ឆ្នាំ២០១៨នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ១ ០៩៣ករណី ដោយពិន័យអន្តរការណ៍ចំនួន ៥៨២ករណី និងបញ្ជូនទៅតុលាការចំនួន ៥១១ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមាន ឈើមូល-ជ្រុងសរុបចំនួន ៣០០$ម^៣$ ឈើអារចំនួនឈើអារចំនួន ៤ ៨១៨$ម^៣$ គ្រាក់គ្រញូងចំនួន ១១$ម^៣$ សត្វព្រៃចម្រុះប្រភេទ ចំនួន ២ ៣៦២ក្បាល និង១ ៦៦៨គ.ក្រ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត។

## ៤.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានចុះពិនិត្យដល់ទីតាំងជាក់ស្តែងតាមលក្ខណៈបច្ចេកទេសជូនក្រុមហ៊ុនចំនួន២៥ ដែលបានស្នើសុំបន្ត សុពលភាពរោងម៉ាស៊ីនអារ-កែច្នៃឈើចំនួន២៩កន្លែង និងក្រុមហ៊ុនចំនួន១២ ដែលបានស្នើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន១២កន្លែង ព្រមទាំងបានចុះសិក្សាអត្រាកែច្នៃកូនឈើចំនួន៣ក្រុមហ៊ុន

- ក្រុមហ៊ុនចំនួន១១ បានធ្វើការនាំចេញផលិតផលរានទេវតា និងឈើកែច្នៃទៅក្រៅប្រទេសមានបរិមាណ សរុបចំនួន ៤ ៥២៥$ម^៣$ ចំណាំងកម្ទេចឈើចំនួន ៦ ០០០តោន និងជ័រទឹកចំនួន ៣៥២តោន

- ក្រុមហ៊ុនចំនួន៦ បាននាំចូលឈើកែច្នៃពីប្រទេសចិន ម៉ូហ្សំប៊ិច ឥណ្ឌា ម៉ាឡេស៊ី ញ៉ូហ្ស៊ីឡែន និង ប្រទេសកាម៉េរូនមានបរិមាណសរុបចំនួន ៤ ៩៩៤$ម^៣$

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផល អនុផលព្រៃឈើចំនួន១៣ក្រុមហ៊ុន ដែលមានឈើកែច្នៃចំនួន ៦ ៥៤៤$ម^៣$ ឈើអាកាស្យា-ប្រេងខ្យល់កាត់ជាកង់ៗចំនួន ៨ ២៩០ស្ទែរ និងផលិតផលជ័រទឹកចំនួន ៣៣២តោន ព្រមទាំង

បាន ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលផល អនុផលព្រៃឈើចំនួន៧ក្រុមហ៊ុន មានបរិមាណឈើកែច្នៃសរុបចំនួន ៦ ០១០ ម៣។

#### ៤.៧ ការងារចំណូលព្រៃឈើ

- សម្រាប់ឆ្នាំ២០១៨នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន ១៨ ០៣៩ ៦៩២ ៤៧៦រៀល និង១៣៤ ០៩២,១៩ដុល្លារ។

### ៥ ផ្នែកផលិតកម្ម និងបសុព្យាបាល

**៥.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិក្រោមកិច្ចសហការបន្តជាមួយគម្រោង EU-PGA-L។

#### ៥.២ ការងារបសុព្យាបាល

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** ក្នុងឆ្នាំ២០១៨នេះ រាជធានី-ខេត្តចំនួន២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៤៥ ៥៣៦លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ១០ករណី បានកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន ៦៣៨,១គ.ក្រ និងផាកពិន័យតាមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ព្រមទាំងបានណែនាំដល់ក្រុមហ៊ុន និងអាជីវករដែលដឹកជញ្ជូនសត្វរស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញដើម្បីការពារការឆ្លងរាលដាលនៃជំងឺផ្សេងៗ។
- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យជាប្រចាំលើទីតាំងស្នើសុំបង្កើត និងបន្តសុពលភាពសត្តឃាតដ្ឋាន ប្រភេទ «ក» និង«ខ» តាមបណ្តារាជធានី-ខេត្តចំនួន៤ និងចុះពិនិត្យតាមដាន វាយតម្លៃការងារសត្តឃាតដ្ឋានតាមបទដ្ឋានបច្ចេកទេស អនាម័យសត្វនិងផលិតផលសត្វនៅខេត្តព្រះវិហារ បន្ទាយមានជ័យ បាត់ដំបង ស្ទឹងត្រែង កំពង់ឆ្នាំង កំពង់ស្ពឺ ត្បូងឃ្មុំ កំពង់ធំ និងប៉ៃលិន។
- **ការងារផ្សព្វផ្សាយបច្ចេកទេស៖**ចុះតាមដានការថែទាំដំណាំចំណីសត្វរបស់កសិករ ផ្សព្វផ្សាយជំងឺឆ្លងសត្វ វិធានការការពារ រៀបចំបោះពុម្ពបដាពាក្យស្លោកអប់រំ ផ្ទាំងរូបភាព និងសៀវភៅបច្ចេកទេសចិញ្ចឹមសត្វ។
- **ការងារនីតិកម្មនិងវិវាទ៖**

- សម្រេចបានលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វចំនួន ៣ប្រកាស
- កំពុងធ្វើបន្តព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈបសុពេទ្យ
- កំពុងធ្វើបន្តអនុក្រឹត្យ ប្រកាសស្តីពី ការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វនិងកន្លែងច្នៃបឋមផលិតផលសត្វ ឯកសណ្ឋានសញ្ញាសម្គាល់និងឋានន្តរសក្តិ គំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ នីតិវិធីត្រួតពិនិត្យអនាម័យបសុព្យាបាល នីតិវិធីការចេញលិខិតអនុញ្ញាតវិញ្ញាបនបត្របសុព្យាបាល និងបច្ចេកទេសចរាចរណ៍សត្វ បទដ្ឋានបច្ចេកទេសការដឹកជញ្ជូនបសុឱសថ នីតិវិធីការគ្រប់គ្រងបសុឱសថ និងវត្ថុធាតុជីវបសុព្យាបាលធ្វើពាណិជ្ជកម្មនិងការលាយផ្សំ នីតិវិធីការចេញលិខិតអនុញ្ញាតបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់កន្លែងព្យាបាលសត្វ កន្លែងប្រមូលផ្តុំសត្វ និងកន្លែងអាជីវកម្មសត្វ។

#### ៥.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ១៣ ៤១៨វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី។ ជាក់ស្តែង ឆ្នាំ២០១៨នេះ មានផ្ទុះជំងឺផ្តាសាយបក្សីចំនួន ៧ករណី នៅរាជធានីភ្នំពេញ ខេត្តមណ្ឌលគិរី កណ្តាល ព្រៃវែង សៀមរាប និងខេត្តត្បូងឃ្មុំ។

- ការងារស្រាវជ្រាវផលិតកម្ម៖ បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៧ក្បាល ក្នុងនោះគោប្រាម៉ាន់កាត់ ៣៣ក្បាល កូនគោបៅដោះ ៣៤ក្បាល គោកំផែងសែន ៤០ក្បាល។ ដោយឡែក នៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ២០៣ក្បាល។

## ៦ ផ្នែកជលផល

### ៦.១ ការអភិរក្សធនធានជលផល

- អភិរក្សផ្កាថ្ម ស្មៅសមុទ្រចំនួន ៤ ០៥០ហ.ត នៅតាមតំបន់ឆ្នេរ
- ដាំព្រៃលិចទឹក និងព្រៃកោងកាងបានចំនួន-៨០ហ.ត
- រៀបចំអន្លង់ត្រីមេពូជបានចំនួន ៩៧កន្លែង នៅតំបន់មេគង្គលើក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង
- បានលែងកូនត្រី និងកូនបង្កងចំនួនជាង ៤លានក្បាល ទៅក្នុងបឹងធម្មជាតិ
- បានលែងកូនកន្ធាយក្បាលកង្កែបចំនួន ៣៨០ក្បាល ចូលក្នុងដែនទឹកធម្មជាតិ
- បានអភិរក្សធនធានជលផលកំពុងរងគ្រោះថ្នាក់ដូចជាអណ្តើកសរសៃ អណ្តើកសមុទ្រ កន្ធាយក្បាលកង្កែប ក្រពើ ត្រី ផ្សោតទឹកសាប ផ្សោតទឹកប្រៃ និងសេះសមុទ្រ។ល។ ដែលធ្វើឱ្យចំនួនកើនឡើងចន្លោះពី០៥-១០%
- បានទម្លាក់ប្រអប់បេតុងចំនួន ១៥៥ប្រអប់ សម្រាប់ជាជម្រកសិប្បនិម្មិត និងរាំងការនេសាទដោយអួនអូស
- បានទទួលការចុះបញ្ជីកសិដ្ឋានចិញ្ចឹមក្រពើចំនួន ៤០០កសិដ្ឋាន។

### ៦.២ ការអភិវឌ្ឍន៍វារីវប្បកម្ម

- ការចិញ្ចឹមត្រីអនុវត្តបាន២៥៤ ០៤៨តោនបើប្រៀបធៀបរយៈពេលដូចគ្នាកើនឡើងចំនួន៤៦ ៦០៥តោនស្មើនឹង22,47%
- ការចិញ្ចឹមក្រពើឆ្នាំ២០១៨ អនុវត្តបានចំនួន ៤១០ ០០០ក្បាល កើនលើសឆ្នាំមុនចំនួន ១៧ ២២៣ក្បាល
- ផលិតកូនត្រីពូជបានចំនួន ២១០ ០០០ ០០០ក្បាល កើនលើសឆ្នាំមុនចំនួន ៥ ០០០ ០០០ក្បាល។

### ៦.៣ ការបង្កើតស្រះជម្រកត្រីសហគមន៍

- បានបង្កើតស្រះជម្រកត្រីសហគមន៍ចំនួន ៨៦៤កន្លែង គិតរហូតដល់ឆ្នាំ២០១៨នេះ ខេត្តកំពង់ស្ពឺមានចំនួនច្រើនជាងគេរហូតដល់ចំនួន ១៧៣កន្លែង។

### ៦.៤ ស្ថិតិជលផល

- ផលត្រីមានចំនួនសរុប ៩១០ ១៥៣តោន កើនលើសឆ្នាំមុនចំនួន ៥៣ ៨៥០តោន ក្នុងនោះ ផលនេសាទទឹកសាបចំនួន ៥៣៥ ០០៥តោន ផលនេសាទសមុទ្រចំនួន ១២១ ១០០តោន ផលវប្បកម្មចំនួន ២៥៤ ០៤៨តោន។

### ៦.៥ ការបង្ក្រាបបទល្មើសជលផល

- ក្នុងឆ្នាំ២០១៨នេះ សំណុំរឿងនៃបទល្មើសជលផលសរុបចំនួន ៣ ១៦៦ករណី (សមុទ្រ២២៨ករណី) ប្រៀបធៀបឆ្នាំមុនថយចុះចំនួន ៧៥៩ករណី ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន ២ ៩៧៨ករណី ពិន័យអន្តរការណ៍ចំនួន ១១៤ករណី បញ្ជូនទៅតុលាការចំនួន ៧៤ករណី ជាប់ពន្ធនាគារចំនួន២នាក់។ ចំពោះវត្ថុតាងរឹបអូស និងបំផ្លាញចោលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង ១ ៣៤៤ ៦០៤ម៉ែត្រ បង្គោល/ចម្រឹងចំនួន ៥៣៣ ៣៩៦ដើម លូស្បៃមុង និងសាច់អួនចំនួន ១៩ ៥១៣មាត់ ឧបករណ៍ឆក់ត្រីចំនួន ៣៨២គ្រឿង របាំងព្រួលចំនួន ១ ២១៦ម៉ែត្រ សម្រាស់ចំនួន ៥០ ៧៨២ ម៉ែត្រក្រឡា លែងត្រីចម្រុះចូលក្នុងធម្មជាតិចំនួន ៧២ ៩៦៧គ.ក្រ។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បញ្ចេញពូជដំណាំចំនួន ២ពូជ គឺពូជស្រូវផ្កាមាលតី និងពូជសណ្តែកដី១ពូជ គឺពូជខេប១ (CAP1=Cambodian Peanut) ជូនកសិករប្រើប្រាស់ និងបានប្រមូលសំណាកដំណាំស្រូវ ម្រះ ចេក និងដំណាំផ្សេងៗទៀតចំនួន ២៥០សំណាកយកមកអភិរក្សនិងប្រើប្រាស់បន្ថែមទៀត ព្រមទាំងវាយតម្លៃនិងកំណត់លក្ខណៈសំណាកម្ទេសចំនួន ៩៥សំណាក គ្រសក់ស្រូវចំនួន ៦១សំណាក និងល្ពៅចំនួន ១៧សំណាក

- បានធ្វើពិសោធន៍ និងស្រែបង្ហាញចំនួន ៨៥ប្រភេទ ក្នុងនោះមានពិសោធន៍ចំនួន ១៩៣កន្លែង និងស្រែបង្ហាញចំនួន ៤៩៣កន្លែង និងបានធ្វើអង្កេតចំនួន ៧ប្រភេទលើកសិករចំនួន ៦ ៩០០នាក់ ដោយបានស្រាវជ្រាវឃើញបច្ចេកវិទ្យាថ្មីៗចំនួន ៩បន្ថែមទៀត។ ធ្វើទិវាស្រែចំនួន ១៥លើក មានកសិករចូលរួម ៥៦០នាក់ វគ្គបណ្តុះបណ្តាលកសិករចំនួន ១៥លើកមានកសិករចូលរួម ៦៩៥នាក់ និងវគ្គបណ្តុះបណ្តាលជំនាញនៅវិទ្យាស្ថានចំនួន ៣លើកមានអ្នកចូលរួម ៨៣នាក់

- បានលក់គ្រាប់ពូជស្រូវគ្រប់ចំណាត់ថ្នាក់ជូនអតិថិជនចំនួនប្រមាណ ៨,១តោន និងបានផ្តល់គ្រាប់ពូជតាមការស្នើសុំអន្តរាគមន៍ពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងក្រុមការងារចុះពង្រឹងមូលដ្ឋានចំនួនជាង ១៥តោន។ ចែកគ្រាប់ពូជស្រូវនិងបង្រៀនពីផលិតកម្មគ្រាប់ពូជជូនដល់កសិករចំនួន ៣០០គ្រួសារ ដែលដាំដុះលើផ្ទៃដីសរុបចំនួន ២៧ហ.ត ទទួលបានបរិមាណគ្រាប់ពូជចំនួន ៧០តោន។ ទន្ទឹមនឹងនេះ បានផលិតគ្រាប់ពូជស្រូវនៅក្នុងវិទ្យាស្ថានបានប្រមាណ

៤៥តោន។ រៀបចំអង្គរពូជស្រូវផ្កាមាលតីជូនប្រមុខនិងថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ព្រមទាំងថ្នាក់ដឹកនាំក្រសួងភ្ញៀវកសជាតិ ចំនួន ១ ០២៥គ.ក្រ

- បានដឹកនាំ និងចូលរួមសរសេរអត្ថបទវិទ្យាសាស្ត្រនិងបោះពុម្ពនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រនានាដោយជោគជ័យបានចំនួន ៧អត្ថបទ និងបានដឹកនាំនិស្សិតសរសេរសារណាបរិញ្ញាបត្រចំនួន ៣នាក់ និងបណ្ឌិត ១នាក់ ចប់ដោយជោគជ័យ

- បានបោះពុម្ពឯកសារឡើងវិញចំនួន ២៨ ៧០០ច្បាប់ និងមានអ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យារបស់វិទ្យាស្ថានតាមរយៈគេហទំព័រ http://www.cardi.org.kh សរុបចំនួន ៦៥១ ៦៥៧នាក់។

## ៨ ផ្នែកនីតិកម្មកសិកម្ម

### ៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជីកាសម្ភារកសិកម្មបានចំនួន ២២១ក្រុមហ៊ុន សរុបចំនួន ២ ៣០៩មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ២០៦ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥៤ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤៦ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៧ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៩៦ក្រុមហ៊ុន សរុបចំនួន ៦៤៧សំណាក។

### ៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម
- បានរៀបចំសិក្ខាសាលាស្តីពីវិធាន និងនីតិវិធីប្រតិបត្តិពាណិជ្ជកម្មលើធាតុចូលក្នុងផលិតកម្មកសិកម្មចំនួន២លើក
- បានពិនិត្យ និងផ្តល់មតិលើករណីផ្សេងៗគ្នាចំនួន ១៤ករណី។

### ៨.៤ ការងារអនុវត្តច្បាប់

- បានចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសតាមរាជធានី-ខេត្តគោលដៅចំនួន ១៥លើក និងពិន័យអន្តរការណ៍ចំនួន ៤៤ករណី មានក្រុមហ៊ុនចំនួន១ និងដេប៉ូចំនួន៤៣ ស្មើនឹងទឹកប្រាក់ចំនួន ៧០ ៧០០ ០០០រៀល។

## ៩ ផ្នែករដ្ឋបាល

- ក្នុងឆ្នាំ២០១៨នេះ បានទទួលលិខិតសរុបចំនួន ៩ ៣១៦ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៣ ៧២៧ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣ ៩៣១ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១ ៦៥៨ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១២ ៥៩៤ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៥៨៩ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ២៣៨ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៧៩៤នាក់ ក្នុងនោះស្រីចំនួន ១ ៦០៤នាក់ ស្មើនឹង ២៣% រួមមាន៖

  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៨៨៣នាក់ ក្នុងនោះស្រីចំនួន ៨១៥នាក់ ស្មើនឹង ២៨%
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ៣ ៩១១នាក់ ក្នុងនោះស្រីចំនួន ៧៨៩នាក់ ស្មើនឹង ២០%

- បានតែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបមានចំនួន១៥១នាក់ ស្រីចំនួន៣៣នាក់

- បានចេញប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌមានចំនួន ៥៣នាក់ ស្រី៥នាក់ ក្នុងនោះ បោះបង់ចោលការងារមានចំនួន ១២នាក់ ស្រី១នាក់ សុំលាឈប់ពីការងារមានចំនួន ៧នាក់ ស្រី៤នាក់ និងមរណភាព មានចំនួន ៣៤នាក់

- បានចេញប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងមានចំនួន ១០នាក់ ផ្ទេរចូលក្នុងក្រសួងមានចំនួន ១៦នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងមានចំនួន ៦០នាក់

- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារមានចំនួន ១៣៩នាក់ ស្រីចំនួន ៩១នាក់ ក្នុងនោះមាន៖ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំមានចំនួន ៦៨នាក់ ស្រីចំនួន ២៣នាក់ ច្បាប់ព្យាបាលជំងឺមានចំនួន ១៤នាក់ ស្រីចំនួន ១១នាក់ និងច្បាប់សម្រាកមាតុភាពមានចំនួន ៥៧នាក់

- បានចេញប្រកាសដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សមានចំនួន ៣៩នាក់ ស្រីចំនួន ១០នាក់

- បានចេញប្រកាសឲ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញមានចំនួន ១០៥នាក់ ស្រីចំនួន ២០នាក់

- បានចេញប្រកាសដាក់មន្ត្រីឲ្យចូលនិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈមានចំនួន ១៧៨នាក់

- បានចេញប្រកាសដំឡើងថ្នាក់ជូនមន្ត្រីរាជការសម្រាប់ឆ្នាំ២០១៧ចំនួន ១ ៩០៥នាក់ ក្នុងនោះ អង្គភាពថ្នាក់កណ្តាលចំនួន ៩១៤នាក់ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៩៩១នាក់

- ការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ២ ៩២៣នាក់ ស្រី៦៥២នាក់ ក្នុងនោះមាន៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមចំនួន ២ ២៨០នាក់ និងរយៈពេលវែងមានចំនួន ៧នាក់
  + ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ៦៣៦នាក់ ក្នុងនោះ ការបណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យមចំនួន ៦១៦នាក់ ស្រី១៧៨នាក់ និងរយៈពេលវែងចំនួន ២០នាក់ ស្រី១០នាក់។

## ១១ មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានបញ្ចប់នូវការបង្កើតគេហទំព័រថ្មីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ព្រមទាំងកម្មវិធីទូរស័ព្ទឆ្លាតវៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Mobile App) ក៏បានបញ្ចប់ការបង្កើត និងកំពុងបញ្ចូលព័ត៌មាន ដើម្បីប្រកាសដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ២០១៩ ខាងមុខ

- បានចុះដំឡើងគេហទំព័រដែលបានបង្កើតរួចជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ព្រមទាំងបានបណ្តុះបណ្តាលក្នុងការគ្រប់គ្រង និងប្រើប្រាស់គេហទំព័របានចំនួន ១២រាជធានី-ខេត្ត

- បានចុះតាមដានការអនុវត្តលើការប្រើប្រាស់គេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ០៨ខេត្ត មានដូចជា៖ កំពង់ស្ពឺ កំពង់ចាម កំពង់ឆ្នាំង កំពត កែប ព្រះសីហនុ ស្ទឹងត្រែង និងបាត់ដំបង

- បានបង្កើតគេហទំព័រប្រព័ន្ធទិន្នន័យព័ត៌មានភូមិសាស្ត្រកសិកម្ម ប្រមូលទិន្នន័យដំណាំកសិកម្ម បញ្ចូលទិន្នន័យទីតាំងពាក់ព័ន្ធនឹងផលិតកម្ម ការប្រមូលទិញ និងកែច្នៃផលិតផលកសិកម្ម ទៅក្នុងប្រព័ន្ធមានចំនួន ១ ៣៥២កំណត់ត្រាទិន្នន័យ បញ្ចូលទិន្នន័យដំណាំស្រូវវស្សា ស្រូវប្រាំង ដំណាំរួមផ្សំដូចជាពោត ដំឡូងឈើ ដំឡូងមី សណ្តែកសៀង សណ្តែកដី ល្ង និងដំណាំកសិកម្មរួមមានដំណាំកៅស៊ូ ស្វាយចន្ទី។ ទន្ទឹមនឹងនោះ បានបញ្ចូលទិន្នន័យក្នុងប្រព័ន្ធមានឃ្លាំងស្តុកស្រូវ ឡសម្ងួត រោងម៉ាស៊ីនកិនស្រូវបាន ៧៧ទីតាំង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តសរុប ៩២ទីតាំង

- បានផលិតវីដេអូបច្ចេកទេសកសិកម្មចំនួន ០៥វីដេអូ ដើម្បីជំរុញការផ្សព្វផ្សាយតាមរយៈគេហទំព័រក្រសួង និងបណ្តាញផ្សព្វផ្សាយសង្គម (ហ្វេសប៊ុក) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- រៀបចំសិក្ខាសាលាចំនួន ២វគ្គស្តីពី "ការពិនិត្យវឌ្ឍនភាពនៃរបៀបប្រើប្រាស់ និងគ្រប់គ្រងគេហទំព័ររបស់អង្គភាពក្រោមឱវាទ និងអមទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ"

- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលចំនួន ២វគ្គស្តីពី "ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យកសិកម្ម"

- បានដាក់ឲ្យដំណើរការគេហទំព័របណ្ណាល័យកសិកម្មអេឡិចត្រូនិក ដែលមានភាពទាក់ទាញ និងសម្បូរដោយឯកសារបច្ចេកទេសកសិកម្ម ដើម្បីជាផលប្រយោជន៍លើការសិក្សាស្រាវជ្រាវដល់មន្ត្រីរាជការ សាធារណជនទូទៅ សិស្សនិស្សិត។

## ១២ ផ្នែកផែនការនិងស្ថិតិ

- បានពិនិត្យផ្តល់យោបល់ និងរៀបចំលិខិតឆ្លើយតបលើការងារស្រូវពូជដែលជាសំណើរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលសន្និធិចុងគ្រាឆ្នាំ២០១៧ ស្រូវពូជសល់ពីការស្តារផ្ទៃដីខូចខាតដោយគ្រោះធម្មជាតិមានចំនួន ២៦៨,៤៨តោន បច្ចុប្បន្នបានបញ្ចេញដោះដូរចំនួន ២២១,៧៣តោន

- លើកសំណើសុំទៅរាជរដ្ឋាភិបាលដើម្បីជម្រះបំណុលអន្តរាគមន៍ និងការបាត់បង់ដោយសារការផ្លាស់ប្តូរស្រូវពូជចាស់ ប្តូរយកស្រូវពូជថ្មីសរុបចំនួន ៣ ៣៣១,០២តោន

- ចុះពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីចំនួនសន្និធិស្រូវពូជដែលនៅសល់នៅខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ តំពង់ចាម ពោធិ៍សាត់ បាត់ដំបង និងខេត្តប៉ៃលិន

- ការបញ្ចេញពីសន្និធិគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយលើការងារអន្តរាគមន៍ស្តារការខូចខាតដោយទឹកជំនន់មេគង្គ អគ្គនាយដ្ឋានកសិកម្មផ្តល់ស្រូវពូជចំនួន ២ ១៩៨,៩៥តោន និងគ្រាប់ពូជបន្លែមានចំនួន ៧៩ ៣៧៩កញ្ចប់

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំរបាយការណ៍វឌ្ឍនភាពលើការអនុវត្តគម្រោង និងការរៀបចំព្រឹត្តិបត្រព័ត៌មានពាក់ព័ន្ធនឹងគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចចំនួន ៦ខេត្ត គឺខេត្តកំពង់ចាម កោះកុង ពោធិ៍សាត់ បាត់ដំបង រតនគិរី និងខេត្តមណ្ឌលគិរី

- បានចូលរួមពិនិត្យ និងដោះស្រាយតាមការស្នើសុំពីសហភាពអឺរ៉ុបពាក់ព័ន្ធនឹងទំនាស់ដីធ្លីរវាងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចកោះកុងស៊ូហ្គ័រ និងប្រជាពលរដ្ឋ

- បានរៀបចំសិក្ខាសាលាស្តីពីការផ្សារភ្ជាប់កសិករមកទីផ្សារ និងរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីផលប៉ះពាលបរិស្ថានក្នុងផលិតកម្មកសិកម្ម

- បានរៀបចំសិក្ខាសាលាស្តីពីបច្ចេកទេសវិទ្យាព័តមានលើការប្រមូល និងប្រើប្រាស់ទិន្នន័យសម្រាប់ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងកសិកម្ម។

## ១៣ ផ្នែកសវនកម្មផ្ទៃក្នុង

- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០ ផែនការថវិកាឆ្នាំ២០១៨ និងផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០១៨

- បានបើកវគ្គបណ្តុះបណ្តាលចំនួន ៦វគ្គ និងសិក្ខាសាលាចំនួន ១លើក ស្តីពីជំនាញសវនកម្ម

- បានចុះធ្វើសវនកម្មចំនួន ៤៦សវនដ្ឋាន ស្មើនឹង១០០%នៃផែនការ ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន ៣៩៤អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥០%នៃផែនការចំនួន ៤៨%

- ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសវនដ្ឋានត្រូវបង្កើតបន្ថែម បង្កើតរចនាសម្ព័ន្ធគ្រប់គ្រងស្ថានីយ និងកសិដ្ឋានចិញ្ចឹមសត្វ។

## ១៤ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានសម្របសម្រួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសអាស៊ានចំនួន២លើក និងរៀបចំដំណើរការកិច្ចប្រជុំនៅក្នុងឆ្នាំ២០១៨

- បានសម្របសម្រួលកិច្ចប្រជុំរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងព្រៃឈើអាស៊ានលើកទី៤០ និងកិច្ចប្រជុំអមមួយចំនួនផ្សេងទៀត ព្រមទាំងសិទ្ធិប្រទានចុះហត្ថលេខា

- បានសម្របសម្រួលសុំការយល់ព្រមលើការផ្តល់លិខិតតុបករណ៍បញ្ជាក់ការទទួលស្គាល់លើកិច្ចព្រមព្រៀងស្តីពីការបង្កើតមជ្ឈមណ្ឌលសម្របសម្រួលអាស៊ានសម្រាប់សុខភាពសត្វ និងជំងឺស៊ូណូស

- បានចុះអនុស្សរណៈយោគយល់គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមួយបណ្តាប្រទេស និងដៃគូអភិវឌ្ឍន៍

- បានសម្របសម្រួលការងារជាមួយអង្គភាពជំនាញក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម ដើម្បីពិនិត្យនិងលើកជាសំនួរសម្រាប់ការបកស្រាយពីភាគីចិនស្តីពី របាយការណ៍ត្រួតពិនិត្យឡើងវិញនៃគោលនយោបាយពាណិជ្ជកម្មរបស់ចិនលើកទី៧ ព្រមទាំងភាគីសហរដ្ឋអាមេរិកស្តីពី របាយការណ៍ត្រួតពិនិត្យឡើងវិញនៃគោលនយោបាយពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកលើកទី១៤ ទៅតាមអនុវិស័យកសិកម្ម ផលិតកម្មនិងសុខភាពសត្វ កៅស៊ូ និងព្រៃឈើ។

## ១៥ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១៥.១ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៧-២០១៨ សរុបមានចំនួន ៣ ១០០នាក់ (ស្រី១ ០៩១នាក់) ចែកចេញជា ១០មហាវិទ្យាល័យគឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមសម្រាប់ការបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- គ្រប់មហាវិទ្យាល័យបានបញ្ចប់កម្មវិធីសិក្សាក្នុងខែធ្នូរបស់ខ្លួន ហើយបានដឹកនាំនិស្សិតចុះធ្វើកម្មសិក្សានៅតាមសហគមន៍ ក្រុមហ៊ុនឯកជន កសិដ្ឋានកសិកម្ម

- បានរៀបចំពិធីបំពាក់កន្សែងក្រហមជូននិស្សិតក្លឹបកាកបាទក្រហមកម្ពុជាប្រចាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំនួន១០០នាក់ និងបានចូលរួមប្រឡងប្រកួតប្រជែងសម្តែងសិល្បៈ ក្នុងមហោស្រពសិល្បៈជាតិទូទាំងប្រទេសឆ្នាំ២០១៨ ទទួលបានចំណាត់ថ្នាក់លេខ២កម្រិតឧត្តមសិក្សា។

## ១៥.២ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ សរុបចំនួន ៩២០នាក់ (ស្រី៣២៩នាក់) ក្នុងនោះ និស្សិតថ្នាក់បរិញ្ញាបត្រចំនួន ៧០៣នាក់ (ស្រី២៥៤នាក់) និងនិស្សិតថ្នាក់បរិញ្ញាបត្ររងចំនួន ២១៧នាក់ (ស្រី៧៥នាក់) លើជំនាញៈ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសួនរុក្ខជាតិ

- បានចូលរួមសិក្ខាសាលាចែករំលែកចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ ក្រោមប្រធានបទការពង្រឹងភាពធន់នឹងអាកាសធាតុនៅសមាគមន៍មូលដ្ឋាននៅប្រទេសកម្ពុជា

- បន្តសហការជាមួយក្រុមហ៊ុនកូរ៉េ Vitrisyste ជំរុញការស្រាវជ្រាវផ្លែកបណ្តុះជាលិកា

- បន្តសហការជាមួយក្រុមហ៊ុនចិន ពិសោធន៍លើការចិញ្ចឹមត្រីបបែលក្បាលកង្កែប

- បានសហការជាមួយ Cambodia-Japan Research Center for Agriculture របស់ក្រុមហ៊ុនជប៉ុនចំនួន៣ មកធ្វើបទបង្ហាញដល់និស្សិតស្តីពីដំណាំចេក។

## ១៥.៣ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៧-២០១៨ សរុបមានចំនួន ៥៨៧នាក់ (ស្រី២៦១នាក់) រួមមានៈ និស្សិតថ្នាក់បរិញ្ញាបត្រចំនួន ៣៣៩នាក់ (ស្រី១៧៨នាក់) និស្សិតថ្នាក់បរិញ្ញាបត្ររងចំនួន ១៣៤នាក់ (ស្រី៥២នាក់) និងនិស្សិតសិក្សាបង់ថ្លៃចំនួន ១១៤នាក់ (ស្រី៣១នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានរៀបចំសិក្ខាសាលាស្តីពីគរុកោសល្យ និងវិធីសាស្ត្របង្រៀន

- បានរៀបចំសិក្ខាសាលាស្តីពីកសិកម្ម និងការបម្រែបម្រួលអាកាសធាតុ

- បានចូលរួមវិធីប្រឡងជ្រើសរើស និងផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកមានស្នាដៃឆ្នើមក្នុងការចិញ្ចឹមសត្វ និងការដាំដំណាំចំណីសត្វ

- សាលាបានសហការជាមួយភាគីជប៉ុនបើកសម្ពោធឱ្យប្រើប្រាស់ Greenhouse សម្រាប់ពិសោធន៍លើគម្រោងដាំចេកអំបូងពណ៌លឿង

- បានពិសោធន៍តាមដានភាពបន្សាំរបស់ពូជល្ហុងប្រេងចំនួនមួយពូជ

- បានបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងវិភាគបាក់តេរី

- បានរៀបចំពិសោធជីកំប៉ុស្តលើដំណាំស្ពៃក្តោប ស្រូវ និងបន្លែផ្សេងៗ។

# III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សានៅទូទាំងប្រទេសបានបញ្ចប់ហើយដោយសម្រេចបានចំនួន ២ ៧៣៥ ៨៤០ហ.ត ស្មើនឹង១០៨,៨៣% នៃផែនការ ២ ៥១៣ ៨៩៥ហ.ត និងការងារប្រមូលផលស្រូវរដូវវស្សាស្មើនឹង ៨៨,៤៧% ទិន្នផលជាមធ្យមទទួលបាន ៣,០៧២តោន/ហ.ត។ ជាមួយនឹងការខិតខំដាំដុះដំណាំរដូវវស្សាយ៉ាងសស្រាក់សស្រាំរបស់ប្រជាកសិករ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ ព្រមទាំងពង្រឹងស្មារតីទទួលខុសត្រូវក្នុងការឆ្លើយតបឲ្យបានទាន់ពេលវេលាលើមូលបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងសារព័ត៌មាននិងបណ្តាញសង្គមផ្សេងៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរ

ការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍវិស័យកសិកម្មក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអន្តរស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- **ទិសដៅអនុវត្តបន្ត**

### **១ ផ្នែកដាំដុះ**

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវរដូវវស្សា និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៨-២០១៩ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញការអនុវត្តសេចក្តីជូនដំណឹងស្តីពីការបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺម៉ូសាអ៊ិច (ជំងឺស្លឹកពពាល) (CMD) លើដំណាំដំឡូងមីឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀត
- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំរួមផ្សំផ្សេងទៀតដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ កាត់បន្ថយការចំណាយថ្លៃដើម និងការប្រើប្រាស់សារធាតុគីមីឱ្យបានច្រើនដើម្បីជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផលរដូវវស្សានេះ និងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ដើម្បីពិនិត្យអំពីវឌ្ឍនភាព បញ្ហាប្រឈម និងការលើកទិសដៅអនុវត្តបន្ត
- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះថ្លៃកសិផលផ្សេងៗជាយថាហេតុ ការងារសម្របសម្រួលថ្នាក់តំបន់ និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋានក៏ដូចជាទីផ្សារកសិផលផ្សេងៗទៀតផងដែរ
- យកចិត្តទុកដាក់តិតគូរផ្សព្វផ្សាយអំពីការប្រើប្រាស់ជីកសិកម្ម ថ្នាំកសិកម្ម និងសារធាតុគីមីផ្សេងៗទៅលើផលិតផលកសិកម្មដែលនាំឲ្យប៉ះពាល់សុខុមាលភាពសាធារណៈ ការនាំចេញកសិផលទៅក្រៅប្រទេស និងលើកកម្ពស់ផលិតកម្មកសិកម្មសរីរាង្គ
- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត់ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ
- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូ
- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ និងធ្វើការវិភាគសេដ្ឋកិច្ចក៏ដូចជាការបញ្ជ្រាបអំពីតម្លៃកៅស៊ូនៅលើទីផ្សារក្នុងកាលៈទេសៈបច្ចុប្បន្ននេះផងដែរ។

### **២ ផ្នែកផលិតកម្មនិងបសុព្យាបាល**

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង
- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស ព្រមទាំងជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី-ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- បន្តពង្រឹងកិច្ចសហការក្នុងក្របខ័ណ្ឌត្រួតពិនិត្យអនាម័យសត្វ និងផលិតកម្មសត្វក្នុងក្របខ័ណ្ឌទ្វេភាគី តំបន់ និងអន្តរជាតិ ព្រមទាំងចូលរួមក្នុងការរៀបចំកិច្ចព្រមព្រៀងទទួលស្គាល់ជំនាញបសុព្យាបាលនៅក្នុងក្របខ័ណ្ឌ ASEAN ដើម្បីសម្រួលដល់ការធ្វើសមាហរណកម្មជំនាញបសុព្យាបាលក្នុងចំណោមប្រទេសសមាជិក ASEAN។

### ៣ ផ្នែកព្រៃឈើ

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីព្រៃឈើជាតិ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចជំនាញ សហគមន៍ព្រៃឈើ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជាលេខ០១ និង០២ របស់រាជរដ្ឋាភិបាល និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

### ៤ ផ្នែកជលផល

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៩ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្គាក្តាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការគ្រប់គ្រងលើការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោឱ្យបានសមស្របតាមវិធានបច្ចេកទេស ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

### ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខុមាលភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិង បណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តសកម្មភាពការងារបង្កើតទម្រង់បន្ថែមលើប្រព័ន្ធគេហទំព័រភូមិសាស្ត្រកសិកម្ម និងរៀបចំទម្រង់នៃការបញ្ចូល ទិន្នន័យព័ត៌មាន ទីតាំងប្រមូលទិញ ទីតាំងលក់ រោងម៉ាស៊ីនកិនស្រូវ ដែលតម្រូវឱ្យ Admin Page បញ្ចូលព័ត៌មានសំខាន់ៗ

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិង ទាន់ពេលវេលា ការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសម ស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារ បច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុង ការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំង ការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់ៗតាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំង ការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តសហការរៀបចំច្បាប់ផ្សេងៗ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកែលម្អ ហេដ្ឋារចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមបែប វិមជ្ឈការនិងវិសហមជ្ឈការនៅតាមអង្គភាពក្រោមឱវាទតាមការចាំបាច់ និងលំដាប់អាទិភាព

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យ នីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា ហើយក៏ជាយន្តការមួយរួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា ពី កសិកម្មបែបវិបុលវប្បកម្មដែលមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិត-ភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលអាកាសធាតុ ស្តង់ដារ ពិសេសការបង្កើន ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម។

ថ្ងៃ ៣ ៨ ១០ ៣ ៩ ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វ៉េង សាខុន**